※本文の複製、転載、改変、再配布を禁止します。

# សំនួរនៅប្រទេសកម្ពុជា

<សំនួរសំរាប់នាយកដ្ឋានកម្មសិទ្ធិបញ្ញា>

## 【1】 ប្រព័ន្ធទូទៅ

### I. អំពីរចនាសម្ព័ន្ធនៃនាយកដ្ឋាន

1.

មន្ត្រីកាន់កាប់បញ្ជីមានប៉ុន្មាននាក់?

2.

មន្ត្រីកាន់កាប់បញ្ជីត្រូវបណ្តុះបណ្តាលយ៉ាងដូចម្តេច? មន្ត្រីកាន់កាប់បញ្ជីធ្លាប់បានឆ្លងកាត់កម្មសិក្សានៅក្រៅប្រទេសដែររឺទេ?

3.

តើមូលដ្ឋានទិន្នន័យ Data Base អំពីម៉ាក ត្រូវបើកចំហរក្រៅពីសំរាប់មន្ត្រីកាន់កាប់បញ្ជីដែររឺទេ? ឧទាហរណ៍ការិយាល័យមេធាវី(ការិយាល័យប្រការនីយបត្រតក្កកម្ម) អាចប្រើប្រាស់បានទេ?

4.

ការបើកចំហរនូវករណីដាក់ពាក្យចុះបញ្ជីម៉ាក អនុវត្តដោយក្រដាសមែនទេ?

### II. សំនួរពាក់ព័ន្ធនឹងសិទ្ធិដាក់ពាក្យ

5.

តើត្រូវចំណាយពេលប៉ុន្មានខែ ចាប់ពីដាក់ពាក្យចុះបញ្ជីម៉ាករហូតដល់ចុះបញ្ជី។

6.

តើមានប្រព័ន្ធផ្តល់សិទ្ធិអោយរហ័សដែររឺទេ? ក្នុងករណីមានបំណង់ចង់ចុះបញ្ជីរហ័ស ថាតើមាននីតិវិធីដាក់ពាក្យយ៉ាងដូចម្តេច?

7.

ចំពោះការកំណត់ប្រភេទទំនិញ រឺសេវាកម្មដែលមានបំណងការពារនោះ ថាតើអាចកត់ត្រាសរុបបានរឺអត់? ដើម្បីចុះបញ្ជីត្រូវកត់ត្រាលំអិតកំរិតណា?

8.

ថាតើម៉ាកជាអក្សរដែលបានពីភាសាក្រៅពីភាសាខ្មែរ អាចចុះបញ្ជីបានដែររឺទេ? ថាតើម៉ាកដែលប្រើប្រាស់តួអក្សរជប៉ុនKanji, Katakana, Hifagana អាចចុះបញ្ជីបានដែររឺទេ?

9.

ចំពោះម៉ាកដែលល្បីនៅបរទេសតែមិនល្បីនៅប្រទេសកម្ពុជា

① ក្នុងករណីមានដាក់ពាក្យចុះបញ្ជីម៉ាក ប្រសិនបើអ្នកដាក់ពាក្យនោះក្រៅពីម្ចាស់ម៉ាកដែលល្បីនៅបរទេស ក៏អាចចុះបញ្ជីម៉ាកបានដែររឺទេ?

② ក្នុងករណីអ្នកដែលក្រៅពីម្ចាស់ម៉ាកនៃម៉ាកដែលល្បីនៅបរទេស កំពុងប្រើប្រាស់ម៉ាកនោះនៅប្រទេសកម្ពុជា ថាតើអាចបង្ក្រាបការប្រើប្រាស់នោះបានរឺអត់? ក្នុងករណីចុះបញ្ជីម៉ាកនៅប្រទេសកម្ពុជានោះជាករណីទុច្ចរិត ថាតើវិនិច្ឆ័យប្រែប្រួលដែររឺទេ?

③ ក្នុងករណីអ្នកដែលក្រៅពីម្ចាស់ម៉ាកនៃម៉ាកដែលល្បីនៅបរទេស ជាម្ចាស់ម៉ាកនៃម៉ាកនោះនៅប្រទេសកម្ពុជា ថាតើអាចបង្ក្រាបការប្រើប្រាស់នោះបានរឺអត់? ម្យ៉ាងទៀតអាចលុបចោលនូវការចុះបញ្ជីម៉ាកនោះបានដែររឺទេ? ក្នុងករណីចុះបញ្ជីម៉ាកនៅប្រទេសកម្ពុជានោះជាករណីទុច្ចរិត ថាតើវិនិច្ឆ័យប្រែប្រួលដែររឺទេ?

10.

យោងតាមមាត្រា១៨នៃអនុក្រឹត មានចែងពីការបដិសេធន៍មិនព្រមចុះបញ្ជីរបស់មន្ត្រីកាន់កាប់បញ្ជី អាចប្តឹងតវ៉ាទៅក្រុមប្រឹក្សាដោះស្រាយបណ្តឹងតវ៉ា រឺទៅតុលាការមានសមត្ថកិច្ច តើក្រុមប្រឹកស្សានោះជាអង្គភាពបែបណា? ម្យ៉ាងទៀតការបណ្តឹងតវ៉ាទៅលើអង្គភាពទាំងពីរនោះមានលក្ខណៈខុសគ្នាដែររឺទេ?

※本文の複製、転載、改変、再配布を禁止します。

11.

នៅពេលដាក់ពាក្យសុំចុះបញ្ជី តើចាំបាច់ប្រើប្រាស់ម៉ាកដែលដាក់ពាក្យនោះនៅប្រទេសកម្ពុជាដែររឺទេ?

12.

ចំពោះសេចក្តីប្រកាសដែលចែងនៅក្នុងមាត្រា២១អនុក្រឹត（Article 21） ក្នុងករណីដាក់សេចក្តីប្រកាសបន្ទាប់ពីខួបលើកទី៥រួចហើយ ចាំបាច់ដាក់ឯកសារដើមទេ គឺមិនបានជាឯកសារចម្លងទេ?

13.

ក្រោយបាន៥ឆ្នាំបន្ទាប់ពីចុះបញ្ជី និងក្រោយបាន៥ឆ្នាំបន្ទាប់ពីការបន្តម៉ាក ហើយក្នុងករណីដាក់សេចក្តីប្រកាសអំពីការមិនប្រើប្រាស់នោះ ថាតើអាចមានករណីលុបចោលនូវការចុះបញ្ជីដែររឺទេ?

14.

គេកំណត់ថាក្នុងពេលដាក់ពាក្យសុំចុះបញ្ជីរឺសុំបន្ត ត្រូវការដាក់គំរូនៃម៉ាកចំនួន១៥ ថាតើត្រូវដាក់អ្វីខ្លះ?

15.

យោងតាមមាត្រា៤(ង)នៃច្បាប់ស្តីពីម៉ាក ពាណិជ្ជនាម និងអំពើនៃការប្រកួតប្រជែងមិនស្មោះត្រង់បានចែងថា ”ម៉ាកដែលដូចគ្នារឺប្រហាក់ប្រហែលដែលនាំអោយច្រឡំគ្នានឹងម៉ាករឺពាណិជ្ជនាមមួយដែលល្បីក្នុងព្រះរាជាណាចក្រកម្ពុជា រឺបង្កើតពីការបកប្រែនៃម៉ាករឺពាណិជ្ជនាមដែលល្បីនោះ សំរាប់ទំនិញរឺសេវាដូចគ្នា រឺប្រហាក់ប្រហែលគ្នា នៃសហគ្រាសមួយទៀត” ត្រូវបដិសេធ ថាតើជាក់ស្តែងព្រំដែននៃការពារម៉ាកនោះមានអនុភាពទៅលើទំនិញស្រដៀងគ្នាដែររឺទេ? ព្រំដែននោះគឺកំរិតប៉ុណ្ណា?